

# ខំតែភ័យ

Hing Sreyrath

San Sopheapanha

Let's Read

The Asia Foundation



ថ្ងៃនេះអ្នកភូមិហែកឋិនទៅវត្ត។
សុធា ក៏ទៅជាមួយពុកម៉ែ និងអ្នកភូមិដែរ។



សុធា រាំឆែយាំធ្វើមុខក្រម៉ិចក្រម៉ើមយ៉ាងសប្បាយជាមួយ
មិត្តភក្តិ។



«ទីងមោងមកហើយ! ទីងមោងមកហើយ! »



សុធា ភ័យស្លន់ស្លោ រត់ចុះ រត់ឡើង!
«ទីងមោង! ទីងមោង! »



សុធា រត់រកមិត្តភក្តិ តែមិនឃើញពួកគេទេ។



សុធា រត់រកឪពុកម្ដាយ តែមិនឃើញពួកគាត់ទេ។



ឬទីងមោងចាប់ពួកគេស៊ីអស់ហើយ?



សុធា ឆ្លេឆ្លា ឃើញពាងនាងក៏រត់ទៅពួនក្បែរនោះ។
«អា ទីងមោងមានជើងពីរដែរ? »



«អា! ទីងមោង ចេះផឹកទឹកដែរ? »



សុធា លូកដៃទៅប៉ះទីងមោង។
សុធា និយាយ៖ «ស្អីរឹងៗ? អា! ក្រដាសទេតើ។
ទីងមោងមិនមែនជាសត្វចម្លែកផងហ្នឹង!»



ទីងមោងបែរមក សុធា ភ្ញាក់ក្រញាង។

«សុធា! » ទីងមោងហៅឈ្មោះនាង។

«សំឡេងនេះ ដូចធ្លាប់ស្គាល់!»



ឪពុក សុធា ចេញពីទីងមោង។ សុធា ស្រឡាំងកាំង «ការពិតជាពុកសោះ កូនខំតែភ័យ ស្មានថាទីងមោងចាប់មនុស្សស៊ី!»



ឪពុក សុធា អស់សំណើច។



ឪពុក សុធា អង្អែលក្បាលនាង៖ «កូនទៅហៅមិត្តភក្តិមករាំវិញមក៏»។
«ចាស ពុក!»



«តាមពិតទីងមោងគឺជាមនុស្សពាក់រូបក្រដាស មិនចេះស៊ីមនុស្សទេ! »
សុធា និយាយប្រាប់មិត្តភក្តិ។



ទីបំផុត សុធា និងមិត្តភក្តិក៏មករាំឆៃយ៉ាំវិញយ៉ាងរីករាយ
ដោយមានទីងមោងរាំក្បែរ៕





Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*ខំតែភ័យ*, Author: Hing Sreyrath. Illustrator: San Sopheapanha. Published by The Asia Foundation - Let's Read, © The Asia Foundation - Let's Read. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2021. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by-nc/4.0/